ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

**អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ**
លេខាធិការដ្ឋានរដ្ឋបាលសរុប

# កំណត់ហេតុកិច្ចប្រជុំពិភាក្សា
# ស្តីពី "ដំណោះស្រាយបញ្ហាពពោះជំនួស" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
# សាលប្រជុំក្រសួងមហាផ្ទៃ ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៧

ឆ្នាំពីរពាន់ដប់ប្រាំពីរ ខែកុម្ភៈ ថ្ងៃទីដប់បួន វេលាម៉ោង ប្រាំបី និងសែសិបនាទី នៅសាលប្រជុំទីស្តីការក្រសួងមហាផ្ទៃ មានរៀបចំកិច្ចប្រជុំពិភាក្សា ស្តីពី"ដំណោះស្រាយបញ្ហាពពោះជំនួស" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់**សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដោយមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ រដ្ឋមន្ត្រី រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ ក្រសួងពាក់ព័ន្ធ ឯកឧត្តម លោកជំទាវ អគ្គនាយក អគ្គនាយករង ប្រធាន អនុប្រធាននាយកដ្ឋាន ប្រធាន អនុប្រធានការិយាល័យ ដែលអញ្ជើញមកពីបណ្តាអង្គភាព ស្ថាប័នពាក់ព័ន្ធមួយចំនួនដូចខាងក្រោម៖

| | | |
|---|---|---|
| ១.ឯកឧត្តម | ហង់ ជួនណារ៉ុន | រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា |
| ២.ឯកឧត្តម | ម៉ម ប៊ុនហេង | រដ្ឋមន្ត្រីក្រសួងសុខាភិបាល |
| ៣.ឯកឧត្តម | អង្គ វង្សវឌ្ឍនា | រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ |
| ៤.ល.ជំរដ្ឋបណ្ឌិត | អ៊ឹង កន្ថាផាវី | រដ្ឋមន្ត្រីក្រសួងកិច្ចការនារី |
| ៥.លោកជំទាវ | ជូ ប៊ុនអេង | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ |
| ៦.ឯកឧត្តម | អ៊ុក គឹមលេខ | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ |
| ៧.ឯកឧត្តម | កើត រិទ្ធ | រដ្ឋលេខាធិការក្រសួងយុត្តិធម៌ |
| ៨.ឯកឧត្តម | ប៉ុល លឹម | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ |
| ៩.លោកជំទាវ | ច័ន្ទ ហារ៉ានវដ្តី | អនុរដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| ១០.ឯកឧត្តម | សុខ វឿន | អគ្គព្រះរាជអាជ្ញារង មហាអយ្យការសាលាឧទ្ធរណ៍ |
| ១១.លោកជំទាវ | សួស រដ្ឋារី | អនុរដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| ១២.ឯកឧត្តម | ស៊ា កុសល | អនុរដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ |
| ១៣.លោកជំទាវ | ប៊ុន ពុទ្ធី | អនុរដ្ឋលេខាធិការក្រសួងកិច្ចការនារី |

| | | |
|---|---|---|
| ១៤.ឯ.ឧ.នាយ | នេត សាវឿន | អគ្គស្នងការ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ |
| ១៥.ឯ.ឧ.នាយ | សុខ ផល | អគ្គនាយក នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ |
| ១៦.ឯ.ឧ.នាយ | ម៉ៅ ច័ន្ទតារា | អគ្គនាយក នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម |
| ១៧.ឯ.ឧ.ឧ.ឯក | ថោង សំអាត | អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ |
| ១៨.ឯ.ឧ.ឧ.ឯក | យឹម វិរៈ | អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ |
| ១៩.ឯកឧត្តម | អ៊ុច ចាន់ណូរ៉ា | អគ្គនាយករង នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម |
| ២០.លោកជំទាវ | មឿង ស៊ាងសេង | នាយករងខុទ្ទកាល័យ |
| ២១.ឯកឧត្តម | ម៉ែន ប៊ុនរិទ្ធ | អគ្គលេខាធិការរង ក្រសួងមហាផ្ទៃ |
| ២២.ឯកឧត្តម | សូរ ឌីម៉ា | អនុប្រធានក្រុមប្រឹក្សានីតិកម្ម |
| ២៣.លោកជំទាវ | រ៉ែន សិរីលក្ខិណា | អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ |
| ២៤.ឯកឧត្តម | ឱ វណ្ណឌីន | អគ្គនាយក ក្រសួងសុខាភិបាល |
| ២៥.ឯ.ឧ.ឧ.ឯក | ហាស់ ម៉េងឡុង | អគ្គនាយករង នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ |
| ២៦.ឯ.ឧ.ឧ.ឯក | ប៉ុល ភិជេយ្យ | ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ |
| ២៧.លោក | រស់ ពិសិដ្ឋ | ចៅក្រម សាលាដំបូងរាជធានីភ្នំពេញ |
| ២៨.លោក | សេង ហៀង | ព្រះរាជអាជ្ញារង អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ |
| ២៩.លោក | គី ខេមលីន | អគ្គនាយករង ក្រសួងយុត្តិធម៌ |
| ៣០.លោកស្រី | សាខឿន សាវ៉ាតឌី | អគ្គនាយករង ក្រសួងកិច្ចការនារី |

**សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ មានប្រសាសន៍ស្វាគមន៍យ៉ាងកក់ក្តៅដល់សមាជិកទាំងអស់ នៃអង្គប្រជុំដែលបានអញ្ជើញចូលរួមនាឱកាសនេះ។ សម្តេចមានប្រសាសន៍ទាក់ទងនឹងអង្គប្រជុំថា រឿងនេះ(ពពោះជំនួស)វាកើតមានយូរហើយនៅប្រទេសថៃ ពេលកូនកើតមកម្តាយក្មេងមិនឲ្យព្រោះកូននឹងវាស្អាត កូនកាត់ នាំគ្នារត់មករកប្រទេសកម្ពុជាវិញម្តង។ មួយទៀត ប្តីប្រពន្ធរបស់គេរួមដំណេកជាមួយគ្នាពេលមានកូនគេបានយកចេញឲ្យអ្នកដទៃពពោះជំនួស ចិញ្ចឹមដាក់ក្នុងកែវ ចង់បានកូនពីរគឺពីរ បីគឺបី ប្រុសគឺប្រុស ស្រីគឺស្រី។ ករណីមួយទៀតអ្នកអត់មានប្រពន្ធចង់បានកូនត្រូវជួលនរណាម្នាក់ជនជាតិណាមួយឲ្យពពោះជំនួស ករណីមួយទៀតគឺប្រពន្ធអត់មានកូនត្រូវជួលគេឲ្យពពោះជំនួស ដោយចាក់បញ្ចូលមេជីវិតទៅស្ត្រីនោះដើម្បីឲ្យមានកូន។ អ្នកស្នើសុំកំពុងតែសុំយកក្មេងចេញ តែយើងមិនអាចធ្វើអ្វីតាមសំណើរបស់ពួកគាត់ទេ។ រឿងរ៉ាវអនាគតនៅវែងឆ្ងាយ ឥឡូវនេះយើងត្រូវគិតពីបញ្ហាចំពោះមុខដែលលួចលាក់ធ្វើប៉ុន្មានករណីទៅហើយ ពេលយើងបញ្ឈប់ទៅចាប់ផ្តើមមានការឈូឆរ បើយើងមិនបានបញ្ឈប់រឿងនឹងវាចេះតែបន្តទៅទៀត ទូតកាណាដាគេនឹងមកជួបខ្ញុំនៅថ្ងៃទី១៥ ឬ១៦ ខែកុម្ភៈនេះ គាត់(ស្ថានទូតកាណាដា) ថាមកនិយាយរឿងកិច្ចសហប្រតិបត្តិការអន្តរជាតិ រឿងសន្តិសុខ រឿងនេះរឿងនោះ តែខ្ញុំមិនជឿទេប្រហែលនិយាយពីរឿងនឹងហើយ

ម្តេចក៏មិនធ្វើនៅស្រុកគាត់? បែរជារត់មកស្រុកយើងហើយមកបង្ខំយើងទៀត។ **សម្តេច** បានអនុញ្ញាតឲ្យលោក **ជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ឡើងធ្វើសេចក្តីរាយការណ៍អំពីករណីពពោះជំនួស ដែលបានអនុវត្តនាពេលកន្លងមកជូនអង្គប្រជុំ។

**លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានឡើងរាយការណ៍ទាក់ទងនឹងបញ្ហាពពោះជំនួស ជូនអង្គប្រជុំ៖ ឆ្នាំ២០១៦ មានការរង្គោះរង្គើ និងមានការស៊ើបអង្កេត រហូតមានការចាប់ឃាត់ខ្លួនដោយស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ អ្នកការសែតអូស្ត្រាលីបានតាមដានបញ្ហានេះថា មានទារកប្រហែលចំនួន ៧០នាក់ដែលបានទៅដល់ប្រទេសអូស្ត្រាលី ហើយស្ថានទូតអូស្ត្រាលីក៏បានទទួលស្គាល់ថា ខ្លួនបានធ្វើការនាំទារកចេញចំនួន១០នាក់ពីកម្ពុជាផងដែរ។ តាមរបាយការណ៍ពីអគ្គនាយកដ្ឋានអន្តោប្រវេសន៍បានឲ្យដឹងថាឆ្នាំ២០១៦ មានការនាំទារកចេញ ដោយការពពោះជំនួសមានចំនួន៣៣នាក់ ចិន១៤, អាមេរិក០៥,ជប៉ុន០៨,អូស្ត្រាលី០៦ មកពីភាពក្រីក្ររបស់ស្ត្រីកម្ពុជា និងស្ត្រីជនជាតិថៃ។ បន្ទាប់ពីតាមដានអស់រយៈពេលជាច្រើនខែឆ្នាំ២០១៦ កន្លងមកនេះ នៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៦ បានឃាត់ខ្លួនជនជាតិអូស្ត្រាលីដែលជាអន្តរការី និងជនជាតិខ្មែរពីររូបម្នាក់ជាគិលានុបដ្ឋាក និងម្នាក់ទៀតជាអ្នកទំនាក់ទំនងរកស្ត្រីពពោះ និងរត់ឯកសារនាំទារកទៅក្រៅប្រទេស។ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សបានធ្វើការកោះប្រជុំពិភាក្សាអំពីបញ្ហាពពោះជំនួសបានចំនួន ០៥លើក៖

-លើកទី១ ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៦

-លើកទី២ ថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៦

-លើកទី៣ ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៦

-លើកទី៤ ថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៦

-លើកទី៥ ថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០១៧

ដោយមានការអញ្ជើញចូលរួមពីបណ្តាតំណាងក្រសួង ស្ថាប័ន អង្គការដៃគូពាក់ព័ន្ធ និងតំណាងស្ថានទូតអូស្ត្រាលីផងដែរ។ យើងបានឲ្យខាងស្ថានទូតអូស្ត្រាលី ផ្អាកការទទួលពាក្យស្នើសុំពាក់ព័ន្ធនឹងការពពោះជំនួសសិនដើម្បីកុំឲ្យមានករណីថ្មីកើតមានឡើង ដោយហេតុថាយើងមានប្រកាសពីក្រសួងសុខាភិបាលបានហាមឃាត់រួចទៅហើយ និងវាបានខុសច្បាប់ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាផងដែរ។ ដោះស្រាយករណីមុនពេលបង្ក្រាបដោយសារប្រជាពលរដ្ឋនៅមិនទាន់យល់ច្បាស់ ដូច្នេះក្នុងករណីនេះយើងគួរតែមានការដោះស្រាយមួយជូនពួកគាត់គឺស្ត្រីពពោះ។ យើងបានធ្វើការសម្របសម្រួលពីស្ថានទូតអូស្ត្រាលីពាក់ព័ន្ធនឹងការផ្តល់ឯកសាររបស់(ថមមី) និងបញ្ជីឈ្មោះអ្នកចង់បានកូន តែខាងអូស្ត្រាលីហាក់បីដូចមិនសូវអើពើពីបញ្ហានេះ ដោយគាត់(អូស្ត្រាលី)ថា ហេតុអីចាប់តែជនជាតិអូស្ត្រាលី ជនជាតិដទៃទៀតមិនចាប់។ យើងចង់ឲ្យពួកគាត់ (អ្នកចង់បានកូន) បន្តជួយឧបត្ថម្ភដល់ស្ត្រីខ្មែរដែលកំពុងពពោះជំនួស បើយើងមានបញ្ជីឈ្មោះអ្នកចង់បានកូនទាំងនោះ យើងអាចឈានទៅរកការឃាត់ខ្លួនក្រុមផ្សេងទៀតបាន ដោយយើងជឿជាក់ថាករណីនេះនៅមានច្រើនទៀត ប៉ុន្តែខាងអូស្ត្រាលីមិនបានផ្តល់មកគ្រប់ចំនួនទេ។ យើងបានធ្វើការផ្សព្វផ្សាយ និងអប់រំ ណែនាំដល់ពួកគាត់ មុនពេលដែលច្បាប់យើងមិនទាន់បាន

សម្រេចឲ្យបានដាក់លាក់ណាមួយនោះ។ អង្គប្រជុំបានសុំឲ្យអគ្គនាយកដ្ឋានអន្តោប្រវេសន៍ និងក្រសួងការបរទេស ធ្វើការសិក្សាលើឯកសារនាំទារកចេញដោយស្របច្បាប់ និងធានាសុវត្ថិភាពឲ្យទារក និងការកេងប្រវ័ញ្ចនានា។ យើងក៏បានឆ្លៀតជួបប្រជុំក្រៅផ្លូវការជាមួយស្ថានទូតអូស្ត្រាលីផងដែរ នៅចន្លោះនៃកិច្ចប្រជុំផ្សេងៗ។ ជាលទ្ធផលយើងបានធ្វើការសហការគ្នារវាង អគ្គនាយកដ្ឋានអន្តោប្រវេសន៍ អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ក្រុមប្រឹក្សានីតិកម្ម ក្រសួងការបរទេស អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ក៏ដូចជាអ្នកពាក់ព័ន្ធបានលើកយកសំណុំឯកសារមកសិក្សានូវចំណុចខ្វះចន្លោះ មានន័យថាឯកសារដែលនាំទារកចេញកន្លងមកមិនទាន់មានសុវត្ថិភាពដល់ទារក និងកុមារនៅឡើយទេ។ ហើយបានឯកភាពកំណត់យកបែបបទនីតិវិធីសមស្របមួយដែលធានាដល់សុវត្ថិភាពកុមារ នៅពេលដែលកុមារបានទៅដល់ប្រទេសគោលដៅ ប្រហាក់ប្រហែលនឹងច្បាប់សុំកូន។ អង្គប្រជុំបានឯកភាពទៅតាមមតិយោបល់ **ឯកឧត្តម កើត រិទ្ធ រដ្ឋលេខាធិការក្រសួងយុត្តិធម៌** លើវិធានការជាជម្រើសពីរ៖ ទី១ ផ្តល់ដំណោះស្រាយតាមច្បាប់ស៊ីវិល បានន័យថា កូនដែលបានពពោះហួសទៅហើយ គិតពីថ្ងៃដែលបានបង្រ្កាបរួចមកកូននឹងកើតមកជាបន្តបន្ទាប់។ ទី២ គឺការដោះស្រាយតាមការពង្រឹងការអនុវត្តច្បាប់ព្រហ្មទណ្ឌក្នុងនោះ មានទាំងច្បាប់ប្រឆាំងការជួញដូរមនុស្ស និងប្រកាសរបស់ក្រសួងសុខាភិបាល ប៉ុន្តែជម្រើសនីមួយៗត្រូវគិតដល់ឧត្តមប្រយោជន៍របស់ទារក និងតាមច្បាប់កម្ពុជាផង និងជាការផ្តល់សិទ្ធិដល់ស្ត្រីជាម្តាយ ដែលជាអ្នកពពោះផង។ វិធានការទាំងពីរនេះមានផលប៉ះពាល់ផ្សេងគ្នា ទី១.តាមក្រមរដ្ឋប្បវេណីមានការបន្ធូរបន្ថយទោសចំពោះអ្នកពាក់ព័ន្ធ អ្នកមានទោសទណ្ឌគឺជាអន្តរការី ហើយក៏មានអ្នកចេញមុខមកស្នើសុំទារកទៀត បានន័យថាទារកនោះនឹងកើតចេញបន្តទៀតប៉ុន្តែពួកគេពុំមានទោសទណ្ឌ រាជរដ្ឋាភិបាលត្រូវធ្វើការហាមឃាត់មិនគួរឲ្យមានករណីនេះកើតមានបន្តទៀតទេ ត្រូវរង់ចាំការបង្កើតច្បាប់ពពោះជំនួសចេញជាស្ថាពរសិន។ ទី២ បើយើងអនុវត្តតាមច្បាប់ព្រហ្មទណ្ឌ គឺករណីពពោះនឹងស្ងប់ស្ងាត់ តែទារកដែលកំពុងនៅក្នុងពោះម្តាយ ឬកើតមកហើយក្តី និងជួបនូវហានិភ័យក្នុងការចិញ្ចឹមបីបាច់ថែរក្សា ការធានាផ្នែកច្បាប់ និងសម្ពាធផ្នែកអារម្មណ៍រហូតមួយជីវិត មានន័យថាកូននឹងខ្វះការទទួលខុសត្រូវពីអាណាព្យាបាល។

ប្រសាសន៍ **សម្តេចក្រឡាហោម**៖ ទី១ យើងត្រូវដោះស្រាយចំពោះករណីដែលកើតឡើងរួចមកហើយ តើយើងសម្រេចចិត្តយ៉ាងណា? ព្រោះថាគេបានលួចលាក់រួចហើយ និងទី២ ត្រូវគិតពីគោលការណ៍សម្រាប់ទៅមុខទៀត តើយើងអនុញ្ញាត ឬមិនអនុញ្ញាត? បើតាមការស្រាវជ្រាវ ឃើញថាប្រទេសដែលហាមឃាត់ដាច់ខាតមានប្រទេស ចិន ជប៉ុន អារ៉ាប់ អារ៉ាប់ប៊ីសាវឌីត បារាំង បែលស៊ីក អ៊ីតាលី អេស្ប៉ាញ ទួគី កេបិច កាណាដា។ ប្រទេសដែលមានការអនុញ្ញាត ក្នុងការស្ម័គ្រចិត្ត មានប្រទេសអាមេរិក អូស្ត្រាលី កាណាដា អង់គ្លេស វៀតណាម។ ប្រទេសអនុញ្ញាតក្នុងសាច់ញាតិឯងមានប្រទេសប្រេស៊ីល ប្រទេសដែលអនុញ្ញតរកប្រាក់ចំណូលដោយស្ម័គ្រចិត្ត មានប្រទេសរុស្ស៊ី ឥណ្ឌា នេប៉ាល់ អាហ្វ្រិកខាងត្បូង ខាងលើនេះតាមការស្រាវជ្រាវរបស់អគ្គលេខាធិការ នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សដែល **ឯកឧត្តម ប៉ុល លឹម** បានលើកឡើង។ បើនិយាយពីទិដ្ឋភាពច្បាប់ត្រូវធ្វើការស្រាវជ្រាវបន្ថែមទៀត ចំពោះបញ្ហាពពោះជំនួស មាត្រា៣៣២ នៃក្រមព្រហ្មទណ្ឌចែងពីបទអន្តរការរវាងអ្នកសុំកូន និងស្ត្រីពពោះ (មានន័យថាច្បាប់យើងបានហាមហើយ)។ ទោសព្រហ្មទណ្ឌក្នុងមាត្រា៣៣២ត្រូវបានកំណត់ចំពោះសកម្មភាពដែលបានប្រព្រឹត្តជាអន្តរការី ក្នុងគោលដៅចង់បានប្រាក់កម្រៃរវាងបុគ្គលម្នាក់ និងអ្នកសុំ

កូនដើម្បីយកទៅចិញ្ចឹម និងស្ត្រីម្នាក់យល់ព្រមពពោះជំនួសដើម្បីប្រគល់កូននោះទៅឲ្យអ្នកសុំ តាមន័យនេះច្បាប់នៃប្រទេសកម្ពុជាបានហាមឃាត់ តែហាក់ពុំទាន់បានកំណត់ទោសទណ្ឌចំពោះបុគ្គល ឬប្តីប្រពន្ធដែលចង់សុំកូនយកមកចិញ្ចឹម និងស្ត្រីដែលព្រមព្រៀងពពោះនោះឡើយ។ ម៉្យាងទៀតបើសិនបុគ្គល ឬប្តីប្រពន្ធដែលចង់បានកូន និងស្ត្រីដែលយល់ព្រមពពោះជំនួសបានឯកភាពគ្នាដោយផ្ទាល់ដោយផ្តល់កម្រៃ ឬមិនផ្តល់កម្រៃ ដែលមិនមានអន្តរការីចូលរួមហើយបានស្វែងរកមន្ទីរពេទ្យស្របច្បាប់ដែលមានបច្ចេកវិទ្យា វិទ្យាសាស្ត្រ វេជ្ជសាស្ត្រសម្រាប់ការពពោះជំនួសនោះ សកម្មភាពនោះអាចមិនស្ថិតក្រោមបទល្មើសដែលចែងក្នុងមាត្រា៣២២ នៃក្រមព្រហ្មទណ្ឌឡើយ មានន័យថាគេហាមតែអន្តរការីទេ។ ចំណែកមន្ទីរពេទ្យដែលមានបច្ចេកវិទ្យា វិទ្យាសាស្ត្រវេជ្ជសាស្ត្រដែលបានផ្តល់សេវាពពោះចំនួននេះអាចត្រូវប្រឈម និងការបំពានទៅលើបញ្ញត្តិ នៃប្រកាស លេខ៦៧៩ប្រ.ក ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ របស់ក្រសួងសុខាភិបាលស្តីពីការគ្រប់គ្រង ឈាម មេជីវិត ខួរឆ្អឹង និងកោសិកាដើមរបស់មនុស្ស។ រាល់ការពពោះជំនួសដែលជាសេវាមួយ នៃការជួយឲ្យមានកូនតាមបែបបច្ចេកទេស វិទ្យាសាស្ត្រត្រូវហាមឃាត់ដាច់ខាត ទោះជាយ៉ាងណាប្រកាសនេះមិនអាចដាក់ទោសទណ្ឌចំពោះសកម្មភាព និងបទល្មើស នៃបទបញ្ញត្តិនេះបានឡើយ។ ចំពោះការបំពេញបែបបទសុំកូន ពពោះជំនួសដែលមិនមែនជាកម្មវត្ថុ នៃបទល្មើសខាងលើ ការរៀបចំឯកសារដើម្បីបំពេញនីតិវិធីផ្ទេរកូន(ទារក) ដែលកើតពីស្ត្រីពពោះជំនួសទៅបុគ្គល ឬប្តីប្រពន្ធដែលសុំនៅក្នុងដែនដីប្រទេសកម្ពុជា តាមមាត្រ១០០៧-១០១៩ នៃក្រមរដ្ឋប្បវេណីស្តីពីការសុំកូនពេញលេញ។ ការរៀបចំឯកសារដើម្បីបំពេញនីតិវិធីផ្ទេរកូន(ទារក) ដែលកើតពីស្ត្រីពពោះជំនួសទៅបុគ្គល ឬប្តីប្រពន្ធដែលសុំត្រូវនាំយកទៅរស់នៅក្រៅប្រទេសកម្ពុជា ត្រូវអនុវត្តតាមច្បាប់ស្តីពីសុំកូនអន្តរប្រទេសដែលបានអនុម័តនៅថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០០៩។ ការរៀបចំឯកសារដើម្បីបំពេញនីតិវិធីផ្ទេរកូន(ទារក) ដែលកើតពីស្ត្រីពពោះជំនួសទៅបុគ្គល ឬប្តីប្រពន្ធដែលសុំ ហើយរស់នៅក្នុងប្រទេសកម្ពុជា ឬដែលត្រូវនាំយកទៅរស់នៅក្រៅប្រទេសកម្ពុជា ដោយមិនមានការអនុវត្តតាមក្រមរដ្ឋប្បវេណី ឬច្បាប់ស្តីពីសុំកូនអន្តរប្រទេសដូចរៀបរាប់ខាងលើ គឺប្រឈមនឹងអនីត្យានុកូលភាពដែលអាចជាកម្មវត្ថុ នៃបទល្មើសព្រហ្មទណ្ឌ តាមមាត្រា៦៣២ នៃក្រមព្រហ្មទណ្ឌស្តីពីបទសុំឲ្យផ្តល់ឯកសារដោយទុច្ចរិត ដែលចែងថា អំពើដែលសុំដោយទុច្ចរិតឲ្យរាជការសាធារណៈចេញឯកសារសម្រាប់ធ្វើការកត់សម្គាល់សិទ្ធិ អត្តសញ្ញាណ ឬឋានៈ ឬយល់ព្រមផ្តល់ការអនុញ្ញាតត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៦ខែ ទៅ២ឆ្នាំ និងពិន័យជាប្រាក់ពីមួយលានរៀល ទៅបួនលាន រៀល។ ដូច្នេះយើងអាចយកច្បាប់នេះមកអនុវត្តសម្រាប់ដោះស្រាយករណីប្រមាណខាងលើនេះបានទេ? សូមដាក់ជូនអង្គប្រជុំ ទៅមុខទៀតតើយើងត្រូវដោះស្រាយយ៉ាងដូចម្តេច? យើងទទួលដោះស្រាយសម្រាប់តែអ្នកដាក់ពាក្យតែប៉ុណ្ណោះ។

ប្រសាសន៍ **ឯកឧត្តម អង្គ វង្សវឌ្ឍនា** រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រឿងនេះវាកើតឡើងតាំងពីឆ្នាំ២០១៦មកម្លេះ ហើយខាងអ្នកសារព័ត៌មានក៏បានជួយផ្សព្វផ្សាយកន្លែងគ្លីនិក ដែលអាចបន្តពូជបាន ទើបមានជនបរទេសមួយចំនួនដោយសារខាងថៃ ប៉ាគីស្ថាន ធ្វើការហាមឃាត់ទើបរត់មកស្រុកខ្មែរ។ ថ្ងៃមុនមានខាងស្ថានទូតចំនួនបីមានអាមេរិក អូស្ត្រាលី កាណាដា ខ្ញុំបានប្រគល់ឲ្យ **ឯកឧត្តម កើត រិទ្ធ** ជាអ្នកជួប គឺមកនិយាយរឿងសុំកូនដែលកំពុងពពោះបើនិយាយឲ្យចំ ដោយសារមានការចាប់ជនជាតិអូស្ត្រាលី ពាក់ព័ន្ធនឹងរឿងជួលស្ត្រីខ្មែរពពោះជំនួស ស្ត្រី

ខ្មែរភ័យខ្លាចសមត្ថកិច្ចចាប់ខ្លួនគាត់ទៀត។ សម្រាប់អ្នកដែលចង់បានកូនគាត់ចង់មកសុំកូនទៅ តែវានៅប្រទាញប្រទង់ជាមួយច្បាប់រដ្ឋប្បវេណីរបស់កម្ពុជាយើងខ្លះ ហើយម្យ៉ាងទៀត ទារកវាជារបស់សម្រាប់ជួញដូរសព្វថ្ងៃនេះគឺខុសនឹងច្បាប់ព្រហ្មទណ្ឌយើង។ ដូច្នេះខ្ញុំសូមប្រគល់ភារកិច្ចនេះទៅឲ្យ **ឯកឧត្តម កើត រិទ្ធ** ដើម្បីធ្វើការពន្យល់បកស្រាយឲ្យខាងស្ថានទូតឲ្យពួកគាត់បានយល់ពីច្បាប់សុំកូន និងច្បាប់ពាក់ព័ន្ធផ្សេងៗ។

ប្រសាសន៍ **ឯកឧត្តម កើត រិទ្ធ** រដ្ឋលេខាធិការក្រសួងយុត្តិធម៌ មុននឹងគោរពរាយការណ៍ជូនសម្តេច និងអង្គប្រជុំ ខ្ញុំបាទសូមជម្រាបជូនអំពីបរិបទរួមដើម្បីរកដំណោះស្រាយឲ្យចំបញ្ហា តាមកិច្ចប្រជុំពិភាក្សាក្រោមអធិបតីភាព **លោកជំទាវ ជូ ប៊ុនអេង** ករណីពពោះនៅកម្ពុជា (**ទី១**) គឺករណីពពោះក្រោមរូបភាពអាជីវកម្ម បើនិយាយឲ្យសាមញ្ញ គឺជាការពពោះតាមរូបភាពការជួញដូរ គឺជាផ្នែកមួយ នៃការប្រឆាំងការជួញដូរមនុស្សផងដែរដែលយើងត្រូវមានការបារម្ភ។ (**ទី២**) ការពពោះដោយយកអំប្រ៊ីយ៉ុង ទៅឲ្យស្ត្រីដើម្បីពពោះ មានន័យថាគឺជាការយកស្ពែម៉ាតូសូអ៊ីត បង្កកំណើតជាមួយនឹងអូវ៉ុល ដោយយកឲ្យស្ត្រីម្នាក់ទៀតពពោះ។ ច្បាប់ប្រទេសកម្ពុជា ក៏ដូចជាប្រទេសដទៃទៀតក្នុងពិភពលោក មិនទាន់មានការផ្លាស់ប្តូរទេទោះបីជាបច្ចេកវិទ្យាជឿនលឿនយ៉ាងណាក៏ដោយ គឺច្បាប់នោះតែងចែងយ៉ាងច្បាស់ថា ស្ត្រីណាដែលជាអ្នកបង្កើតកូន ស្ត្រីនោះគឺជាម្តាយ ហើយជាគោលការណ៍គ្មានបដិប្បញ្ញត្តិទេ។ ច្បាប់ភាគច្រើនរួមទាំងច្បាប់បារាំងផងដែរ គឺចែងច្បាស់ថាឲ្យតែមានភ័ស្តុតាងស្ត្រីជាអ្នកសម្រាលកូននោះ កូននោះគឺជាកូនរបស់ស្ត្រីនោះ ហើយស្ត្រីនោះគឺជាម្តាយរបស់កូននោះ អាចកំណត់បានថាជា ម្តាយតាមផ្លូវច្បាប់ ក្រមយើងបានចែងច្បាស់ក្នុងមាត្រា៩៨៧។ ក្នុងនេះដែរក្រមយើងក៏ចែងទៀតថា ពេលដែលកូនកើតមកដែលមានចំណងអាពាហ៍ពិពាហ៍ជាមួយនឹងបុរសម្នាក់ បុរសនោះត្រូវបានចាត់ទុកជាឪពុករបស់ក្មេងនោះ។ ប៉ុន្តែការចាត់ទុកនេះក្នុងក្រមរដ្ឋប្បវេណី គឺអាចឲ្យមានការបដិសេធបាន ឧទាហរណ៍ក្នុងផ្លូវអាពាហ៍ពិពាហ៍មែនប៉ុន្តែគាត់លួចមានខាងក្រៅ(មានស្រី ឬប្រពន្ធចុង)ហើយមានកូន អ៊ីចឹងអាចមានបុរសផ្សេងទៀតមកទាមទារយកកូននោះបាន សូម្បីតែឪពុកក៏មានសិទ្ធិបដិសេធបានដែរថាមិនមែនជាកូនដោយការពិនិត្យលើ(ឌីអិនអេ)។ បើយើងនិយាយពីករណីពពោះជំនួសវិញ អ្នកដែលយកអំប្រ៊ីយ៉ុង ទៅឲ្យស្ត្រីម្នាក់ពពោះជំនួសដោយស្ត្រីនោះមានចំណងអាពាហ៍ពិពាហ៍រួចទៅហើយមានន័យថាកូននោះគឺជាកូនរបស់ស្ត្រី និងបុរសជាប្តីនោះតាមផ្លូវច្បាប់ ហើយត្រូវឆ្លងទៅតុលាការដើម្បីកំណត់ថារវាងបុរសពីរនាក់នឹងអ្នកណាជាឪពុក មិនមែនយកត្រឹមឯកសារពិនិត្យ ឌីអិនអេ តែមួយមកដើម្បីកាត់ផ្តាច់ចំណងរវាងឪពុកតាមផ្លូវច្បាប់ និងកូនដែលកើតមកនេះទេ គឺត្រូវយកសេចក្តីសម្រេចរបស់តុលាការមួយដើម្បីកំណត់ឲ្យច្បាស់ គ្មានការស្រពេចស្រពិលថាតើអ្នកណាគឺជាឪពុកតាមផ្លូវច្បាប់ និងតាមធម្មជាតិ។ ប៉ុន្តែបញ្ហាពពោះរបស់យើងត្រូវដោះស្រាយ ស្ត្រីដែលពពោះមិនមានជាប់ពាក់ព័ន្ធនឹងចំណងអាពាហ៍ពិពាហ៍នោះទេ។ ដូច្នេះរឿងនេះទាក់ទងនឹងស្ត្រីនៅលីវដែលគាត់ទទួលយកការពពោះជាថ្នូរនឹងកម្រៃ ដូចនេះសំណួរពាក់ព័ន្ធផ្លូវច្បាប់ទាំងអស់នេះខ្ញុំបាទបានជម្រាបទៅទូតថា កម្ពុជាមិនទាន់មានច្បាប់ស្តីពីការពពោះទេ ប៉ុន្តែកម្ពុជាក៏មិនមែនពុំមានច្បាប់គ្រប់គ្រងបញ្ហា នៃការពពោះនោះដែរ មានទាំងក្នុងក្រមព្រហ្មទណ្ឌ មានទាំងក្នុងក្រមរដ្ឋប្បវេណី ហើយទិដ្ឋភាពនៅក្នុងក្រមទាំងពីរនេះអាចយកមកដោះស្រាយក្នុងបញ្ហានេះបាន។ បញ្ហារបស់យើងនៅក្នុងចំណងនេះគឺមានបីនាក់ មានស្ត្រីពីរនាក់ ហើយនិងបុរសម្នាក់ គឺស្ត្រីម្នាក់ជាស្ត្រីពពោះ ស្ត្រីម្នាក់ដែលអាចជាម្ចាស់ នៃអូវ៉ុល និងបុរសម្នាក់ជាម្ចាស់

ស្លែម៉ាតូសូអ៊ីត។ ដូច្នេះបញ្ហារបស់យើងរឿងមួយដែលច្បាស់លាស់ដែលទទួលស្គាល់ទាំងបរទេស ទាំងកម្ពុជាថា កូននោះ គឺពិតជាកូនរបស់ស្ត្រីពពោះព្រោះតាមផ្លូវច្បាប់ សំបុត្រកំណើតដែលចេញដោយមន្ត្រីអត្រានុកូលដ្ឋានក៏គាត់ចេញដូចគ្នាដែរ គាត់ដាក់ម្តាយគឺជាអ្នកពពោះ ហើយពេលដាក់ឪពុកបានដាក់ឪពុកជនបរទេសតែត្រូវធ្វើការផ្ទៀងផ្ទាត់សិនដើម្បីឲ្យច្បាស់ថាស្ត្រីនោះគ្មានចំណងអាពាហ៍ពិពាហ៍មែន។ ផ្អែកលើឯកសារនឹង បុរសជាជនជាតិបរទេសទៅស្នើសុំសញ្ជាតិពីស្ថានទូតរបស់គាត់នៅកម្ពុជាថាក្មេងនេះមានឪពុកជាជនបរទេស និងម្តាយជាខ្មែរ មានន័យថាក្មេងនោះត្រូវបានទទួលស្គាល់តាមផ្លូវច្បាប់ ហើយក្មេងនោះត្រូវមានសញ្ជាតិពីរ គឺសញ្ជាតិខ្មែរ និងសញ្ជាតិរបស់ឪពុកនោះដែលជាម្ចាស់របស់ស្លែម៉ាតូសូអ៊ីត ហើយម្តាយត្រូវបានកំណត់ថាគឺជាម្តាយខ្មែរ មិនដែលកំណត់ថាជាម្តាយបរទេសទេ។ ដូច្នេះស្ថានភាពបញ្ហារបស់យើងកន្លែងនេះ ត្រូវដោះស្រាយយ៉ាងដូចម្តេច? ការទាមទាររបស់ទូតមិនខុសទេ ព្រោះកូននោះមានសញ្ជាតិ នៃប្រទេសរបស់គេ ប៉ុន្តែក្មេងនេះក៏មានសញ្ជាតិខ្មែរដែរ អ៊ីចឹងការដែលរក្សាទុកក្មេងនេះនៅកម្ពុជាគ្មានអីខុសទេ ជាពិសេសនៅក្នុងដំណើរការនៃការស៊ើបអង្កេត។ បញ្ហានេះជាប់ជំពាក់នឹងក្រមព្រហ្មទណ្ឌ គឺការជួញដូរ ត្រឹមមាត្រា៣៣២ គឺកម្ពុជាមិនទទួលស្គាល់ជាផ្លូវការអំពីការពពោះក្នុងន័យ នៃការជួញដូរទេ។ ហើយបើដំណោះស្រាយមិនល្អ ឬចំណាត់ការមិនតឹងរឹង កម្ពុជានឹងក្លាយជាទីផ្សារនៃការពពោះតែម្តង។ ខាងទូតបានសួរថា មានដំណោះស្រាយណាទៀត? ខ្ញុំបានជម្រាបប្រាប់គាត់ថាមានដំណោះស្រាយមួយទៀតគឺដំណោះស្រាយតាមច្បាប់ស៊ីវិល បើដោះស្រាយតាមច្បាប់ស៊ីវិលនេះ គឺអត់យកច្បាប់ព្រហ្មទណ្ឌមកពាក់ព័ន្ធទេ ព្រហ្មទណ្ឌពាក់ព័ន្ធតែអន្តរការីតែមួយបានហើយ។ ខ្ញុំបានលើកយកឧទាហរណ៍ថា មានបុរសជាជនជាតិបរទេសមករស់នៅដោយរួមរស់ជាមួយស្ត្រីខ្មែរ ហើយមានកូនជាមួយគ្នា កូននោះមានសញ្ជាតិពីរ ប្រសិនបើឪពុកចង់បានកូនទៅរស់នៅបរទេសតើខុសច្បាប់ទេ គឺមិនខុសច្បាប់ទេ មានកូនមុនអាពាហ៍ពិពាហ៍ក៏មិនខុសច្បាប់ដែរ។ ប៉ុន្តែការចាត់ចែងនេះ គឺមានទិដ្ឋភាពពីរដែលត្រូវពិចារណា ទីមួយឪពុកម្តាយដែលមានអំណាចមេបាលើកូនមានសិទ្ធិចាត់ចែងឲ្យគាត់ទៅណា? ឧទាហរណ៍ គាត់ចង់រើផ្ទះទៅនៅអាមេរិក អូស្ត្រាលី ឬកាណាដា ឬកន្លែងណា វាជារឿងរបស់គាត់ ជាសិទ្ធិរបស់គាត់ ចង់រស់នៅកម្ពុជាក៏ជាសិទ្ធិរបស់គាត់ បើសិនជាអ្នកទាំងពីរឯកភាពគ្នាត្រឹមត្រូវតាមផ្លូវច្បាប់កូននេះយកទៅបរទេសអត់ខុសទេ ខាងអន្តោប្រវេសន៍អនុញ្ញាតឲ្យចេញទៅក៏មិនមានអីខុស ព្រោះឯកសារបានបញ្ជាក់ហើយថាកូននោះមានសញ្ជាតិបរទេស និងមានការព្រមពីឪពុកម្តាយ បើថ្ងៃក្រោយម្តាយចង់ទៅលេងកូន តើអាមេរិក អូស្ត្រាលី កាណាដា ឲ្យវីសាទេ? ឬគ្រាន់តែបានវេចខ្ចប់យកទៅហើយចោលម្តាយនៅស្រុកខ្មែរ ចុះឯណាសិទ្ធិស្ត្រីជាមួយនឹងកូននោះ? បើយកទៅដាច់ដោយឡែកតែឯងមិនខុសអីពីឪពុកម្តាយឈ្លោះគ្នាហើយប្តឹងទៅតុលាការ សម្រេចឲ្យអ្នកណាម្នាក់មានអំណាចមេបាទៅលើកូនទេ ជាអាណាព្យាបាលតែមួយ ដូច្នេះដំណោះស្រាយដែលល្អគឺប្តឹងបែកសង្វាស់ លំនៅឋានរវាងប្តីប្រពន្ធទាំងពីរ ប្រសិបបើស្ត្រីជាម្តាយយល់ព្រមថាឲ្យកូននេះស្ថិតនៅក្រោមការចាត់ចែងរបស់ឪពុក គឺឪពុកចង់យកទៅណាក៏បានព្រោះគាត់មានសិទ្ធិ មានអំណាចទៅលើកូននោះ។ សូមបញ្ជាក់ថា ខាងទូតមុនគាត់ចេញលិខិតបញ្ជាក់ថាបុរសនោះ គឺជាឪពុកគាត់អត់ផ្អែកទាំងស្រុងលើលិខិតបញ្ជាក់កំណើតរបស់យើងទេ គឺគាត់ត្រូវពិនិត្យ ឌីអិនអេ រវាងកូន និងឪពុកសិនបានគាត់ចេញឲ្យ ដើម្បីគេចឲ្យផុតពីទម្រង់នៃការជួញដូរ។ សូមគោរពបញ្ជាក់ជូនសម្តេចថា ករណីនេះអត់យកទៅប្រើទេប្រសិនបើស្ត្រីនោះមិនយល់ព្រមឲ្យ

យកកូននេះទៅ គឺនីតិវិធីនេះវែងឆ្ងាយណាស់ តែបើព្រមព្រៀងគ្នាវាមិនអីទេ តុលាការគ្រាន់តែចេញកំណត់ហេតុសៈជា គឺមិនត្រូវការចំណាយពេលយូរទេ។ ស្ថានទូតអាមេរិកគាត់សួរមួយថា ចាំបាច់ទៅតុលាការធ្វើអី គេត្រូវតែព្រមព្រៀងគ្នាមានកិច្ចសន្យាថាពេលកូនកើតមកគេអត់យកកូននេះទេ ខ្ញុំបានបញ្ជាក់ថាកិច្ចសន្យានោះគឺខុសច្បាប់ទេ។ ប្រទេសថៃក៏ដូចគ្នានឹងយើងដែរ ពេលកូនកើតមក កូននោះស្អាតហើយម្តាយក្មេងមិនឲ្យយកទៅ គឺគេអនុវត្តដោយមិនអនុញ្ញាតឲ្យយកកូនចេញទៅក្រៅប្រទេសបានទេ ព្រោះច្បាប់ថៃក៏ឯកភាពទទួលស្គាល់ថាម្តាយគឺជាម្តាយស្របច្បាប់របស់កូនហ្នឹង។ បើកម្ពុជាយកដំណោះស្រាយតាមបែបស៊ីវិលមកធ្វើការដោះស្រាយ នោះកម្ពុជានឹងធ្វើឲ្យព័ត៌មាននេះមានការផ្សព្វផ្សាយ ព្រោះរឿងនេះគេតាមសម្លឹមណាស់នៅបរទេស ហើយកម្ពុជាអាចនឹងក្លាយជាគោលដៅ នៃការពពោះ ហើយប្រសិនបើយើងប្រើដំណោះស្រាយច្បាប់ព្រហ្មទណ្ឌដ៏តឹងរឹងបំផុត ខ្ញុំជឿថាករណីមាននៅក្នុងដៃ **លោកជំទាវ ជូ ប៊ុនអេង** និង**ឯកឧត្តម សុខ ផល អគ្គនាយក អគ្គនាយកដ្ឋានអន្តោប្រវេសន៍** មាន១៧ គឺមិនអាចកើនឡើងទៀតឡើយគឺលាក់ទាំងអស់។ ប៉ុន្តែបើប្រើដំណោះស្រាយស៊ីវិលជាដំណោះស្រាយទន់ ដើម្បីជាផលប្រយោជន៍ដល់ក្មេងផង ខ្ញុំជឿថានឹងមានអ្នកមកបង្ហាញថាខ្លួនកំពុងពពោះ ឲ្យអ្នកនេះ អ្នកនោះទាំងអ្នកឆ្លងរួចអាចនឹងមានច្រើនទៀត តើយើងត្រូវគ្រប់គ្រងសភាពការណ៍ និងទទួលដោះស្រាយយ៉ាងដូចម្តេច? ហើយទីបីបញ្ហាប្រឆាំងការជួញដូរមនុស្សទាក់ទងនឹងការពពោះនេះ។ អ្នកសារព័ត៌មានបរទេសក៏កំពុងតាមដានរឿងនេះដែរ បើកម្ពុជាអត់មានច្បាប់ដាក់ទោសទៅលើអ្នកពាក់ព័ន្ធ ហើយមានទោសទៅលើអន្តរការីតែម្នាក់ ពេលគេចាប់បានក៏នៅតែបានកូន ទោះបីមានតែអន្តរការីក៏នៅតែបានកូន។ ដូច្នេះកម្ពុជានឹងក្លាយជាគោលដៅ ឬជាទីផ្សារសម្រាប់ការពពោះទៅថ្ងៃក្រោយតែម្តង។ ខ្ញុំបានពិភាក្សាជាមួយ **លោកជំទាវ ជូ ប៊ុនអេង** លើកយកដំណោះស្រាយចំនួនពីរ គឺដំណោះស្រាយទី១ គឺអន្តរកាល ទី២គឺដំណោះស្រាយទៅថ្ងៃមុខ តាមរយៈការជំរុញជា អាទិភាពច្បាប់ស្តីពីការពពោះ ហើយច្បាប់ពពោះនេះត្រូវមើលគ្រប់ទិដ្ឋភាពទាំងអស់ ទាំងទិដ្ឋភាព នៃផ្នែកស៊ីវិល និងផ្នែកព្រហ្មទណ្ឌ ត្រូវកំណត់តាមគោលនយោបាយរបស់កម្ពុជា(Policies) យើងត្រូវមានការសម្រេចចិត្តមួយឲ្យបានត្រឹមត្រូវ ថាតើត្រូវកំណត់ករណីពពោះជាអំពើស្របច្បាប់ ឬមិនស្របច្បាប់? ប្រសិនបើយើងមានគោលនយោបាយតឹងរឹងមិនឲ្យមាននៅកម្ពុជាតែម្តង ខ្ញុំគិតថាយើងជ្រើសយកច្បាប់ព្រហ្មទណ្ឌសិន។ ខ្ញុំក៏បានបញ្ជាក់ជាមួយខាងទូតដែរថា ដើម្បីផ្តាច់ចំណងឲ្យដាច់ផុតពីក្មេងរវាងម្តាយ និងក្មេងឲ្យផុត គឺត្រូវប្រើប្រាស់ទម្រង់មួយទៀតគឺការសុំកូនពេញលេញ គឺនាំទៅដល់អនុភាពផ្លូវច្បាប់មួយដើម្បីផ្តាច់ចំណងរវាងម្តាយ និងកូនតែម្តង ដូច្នេះក្មេងទោះបីជាយកទៅដល់ស្រុកណាក៏ដោយក៏លែងមានម្តាយនៅកម្ពុជា គឺត្រូវប្រើប្រាស់នីតិវិធីរដ្ឋប្បវេណីដដែល ហើយប្តឹងសុំផ្តាច់តាមរយៈការសុំកូនពេញលេញ។ សូមបញ្ជាក់ថាករណីនេះមិនអនុញ្ញាតឲ្យមានការពពោះជំនួសទេ ហើយឪពុកមិនអាចសុំកូននេះបានទេ ព្រោះជាឪពុកក្មេងរួចទៅហើយ គឺម្តាយជាម្ចាស់អូរ៉ុលជាអ្នកសុំផ្តាច់តាមផ្លូវច្បាប់ ជាមួយក្មេងនៅកម្ពុជា គឺជាការសុំកូនរបស់ម្តាយនៅក្រៅប្រទេស និយាយឲ្យចំគឺជាប្រពន្ធរបស់បុរសនោះដើម្បីឲ្យគាត់មានសិទ្ធិគ្រប់គ្រងក្មេងពេញលេញតាមផ្លូវច្បាប់។ បើកម្ពុជាប្រើប្រាស់នីតិវិធីរដ្ឋប្បវេណី ប្រទេសមួយចំនួនដែលមានចំណងអាពាហ៍ពិពាហ៍ភេទដូចគ្នាដែលប្រទេសមួយចំនួនទទួលស្គាល់ គេនឹងនាំគ្នាមកច្រើនតែម្តង ព្រោះមនុស្សប្រុសមានកូនមកពីណា ដូច្នេះបើ

ច្បាប់កម្ពុជាបង្កើតចេញ ស្តីពីការជួញដូរមនុស្សនៅថ្ងៃក្រោយ ត្រូវគិតលើសេនារីយ៉ូមួយទៀតគឺទាក់ទងករណីប្រើស្ពែម៉ាតូសូអ៊ីត និងអូវ៉ុល ដែលបានមកពីការជួញដូរ មានន័យថាកេម្ពាយឪពុកអត់ឃើញទេ។

ប្រសាសន៍ **សម្តេចក្រឡាហោម ស ខេង** មានចំណុចល្អ និងមិនល្អដែរ ពាក់ព័ន្ធនឹងការប្រើប្រាស់នីតិវិធីទាំងពីរនេះ បើប្រើប្រាស់តាមបែបព្រហ្មទណ្ឌ តឹងរឹងថ្ងៃក្រោយយើងមិនអនុញ្ញាតឲ្យកើតឡើងទៀត ហើយវាបានចូលរួមចំណែកក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស មួយទៀតស្ត្រីខ្មែរយើងខ្លះគាត់មានជីវភាពក្រីក្រ ដើម្បីមានកម្រៃ គាត់ស្ម័គ្រចិត្តពពោះរយៈពេល ៩ខែ១០ថ្ងៃ ហើយក្នុងរយៈពេលនឹងបើគាត់មិនពពោះឲ្យគេគាត់ក៏គ្មានកម្រៃដែរ។ ដូច្នេះយើងត្រូវថ្លឹងថ្លែងលើករណីនេះដែរ។ ឥឡូវវិធានការដែលបានស្នើមកនេះតាមរយៈការប្រជុំមានពីរ ទី១ គឺនីតិវិធីរដ្ឋប្បវេណី អ្នកជាប់ពាក់ព័ន្ធមិនមានទោសទេ មានទោសតែអន្តរការី តែប្រទេសកម្ពុជា នឹងក្លាយជាគោលដៅ ឬអាជីវកម្ម នៃការពពោះ ទី២ គឺនីតិវិធីព្រហ្មទណ្ឌ គឺមានទោសទាំងអស់គ្នា ទាំងអ្នកពពោះ អ្នកជួល និងអន្តរការី ហើយត្រូវប្រើរយៈពេលយូរ។ ចំពោះជម្រើសទាំងពីរនេះ តើយើងគួរជ្រើសរើសយកជម្រើសមួយណាយកមកអនុវត្ត?

ប្រសាសន៍ **ឯកឧត្តម ប៉ុល លឹម** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ខ្ញុំឯកភាពយោបល់ឯកឧត្តម កើត រិទ្ធ យើងត្រូវអនុវត្តតាមបែបស៊ីវិលសិន ចំពោះការផ្តល់នីតិសម្បទាដល់ក្មេងដែលមានបំណងទុក ឬនាំចេញ តាមផ្លូវច្បាប់តាមរយៈតុលាការ មួយទៀតក្រសួងសុខាភិបាលបានចេញប្រកាស ដែលផ្អែកលើបទបញ្ញត្តិ នៃមាត្រា៣២ ច្បាប់ស្តីពីការគ្រប់គ្រងលើការផ្សំកោសិកា និងសិរីរាង្គរបស់មនុស្ស និងហាមលើការពពោះ។ បើយើងធ្វើច្បាប់មួយថ្មីទាក់ទងរឿងនេះ យើងត្រូវធ្វើឲ្យលឿនបើមិនដូច្នេះទេ វានឹងមានបន្តទៀត ធ្វើយ៉ាងណាឲ្យបានច្បាស់លាស់។

ប្រសាសន៍ **លោកជំទាវ បណ្ឌិត អ៊ឹង កន្ថាផាវី** រដ្ឋមន្ត្រីក្រសួងកិច្ចការនារី ពាក់ព័ន្ធនឹងច្បាប់នេះ ក្រសួងកិច្ចការនារីបានរៀបចំបញ្ចប់គ្រោងឆ្អឹងហើយ និងបានបញ្ជូនទៅក្រសួងយុត្តិធម៌ដើម្បីជួយកែសម្រួលបន្ថែម ព្រោះមានទិដ្ឋភាពមួយចំនួនដែលអាចមានការខ្វះចន្លោះ បន្ទាប់មកនឹងធ្វើជូនក្រសួងសុខាភិបាល ដើម្បីកែតម្រូវចំណុចពាក់ព័ន្ធ។ ទាក់ទងនឹងច្បាប់ថ្មីនេះផងដែរ អនុញ្ញាតឲ្យក្នុងករណីមនុស្សធម៌ចំពោះតែក្រុមគ្រួសារខ្មែរតែប៉ុណ្ណោះ មិនមានជនបរទេសចូលទេជៀសវាងការធ្វើអាជីវកម្មកើតឡើង ការពារដល់សិទ្ធិ និងកាត់បន្ថយហានិភ័យដល់ទារក និងម្តាយដែលពពោះ។ ម្យ៉ាងវិញទៀតប្រជាពលរដ្ឋខ្មែរយើងពុំទាន់ដឹងពីករណីពពោះជំនួស គឺជាការខុសច្បាប់ ដូច្នេះយើងអាចមានចំណាត់ការបែបស៊ីវិលមុន ដូចឯកឧត្តម កើត រិទ្ធ មានប្រសាសន៍ពីការស្នើកូនពេញលេញហើយត្រូវធ្វើការផ្សព្វផ្សាយទូលំទូលាយដល់ប្រជាពលរដ្ឋ និងត្រូវគិតថាចាប់ពីពេលណាត្រូវប្រើតាមបែបព្រហ្មទណ្ឌ ហើយមិនចង់ឲ្យស្ត្រីកម្ពុជាក្លាយជាមុខសញ្ញា នៃការធ្វើអាជីវកម្មពពោះ និងការពារសិទ្ធិស្ត្រីផង កុមារផង។ ដើម្បីកុំឲ្យប្រទេសកម្ពុជាក្លាយជាទីផ្សារ នៃការពពោះយើងត្រូវមានវិធានការតឹងរឹង តែត្រូវមានការបន្ធូរបន្ថយចំពោះស្ត្រីដែលកំពុងពពោះ និងឆ្លងទន្លេរួច និងត្រូវគិតគូរដល់ទារកផង តើអ្នកចង់បានកូនមានលទ្ធភាព ចំណូលប៉ុន្មាន? ក្នុងការចិញ្ចឹមបីបាច់ថែរក្សាកូននេះ។

ប្រសាសន៍ **ឯកឧត្តម អ៊ុច ចាន់ណូរ៉ា** អគ្គនាយករង នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ទី១ បញ្ហាអន្តរកាលត្រូវដោះស្រាយ និងកំណត់ពេលវេលាជាក់លាក់ចំពោះករណីទារកកើតហើយ និងទារកដែលមិនទាន់កើត

ចាប់ពីពេលដែលបង្ក្រាបមក ដូច្នេះយើងត្រូវដោះស្រាយតាមបែបរដ្ឋប្បវេណី ស្មុំកូនពេញលេញ តែគួរកុំឲ្យមានការដាក់ទោសទៅលើអន្តរការីអី បើដាក់ទោសលើអន្តរការីវាពិបាកក្នុងការស្រាវជ្រាវបន្ត ជារួមការពពោះជំនួស គឺជាការជួញដូរ និងពាណិជ្ជកម្មតាមរយៈអន្តរការី គឺមិនធ្វើដោយផ្ទាល់ទេ ដូច្នេះយើងកំណត់ពេលវេលា បើហួសពេលវេលាដែលបានកំណត់ គឺយើងត្រូវដាក់ទោសទៅលើអន្តរការី។

ប្រសាសន៍ **ឯកឧត្តម កើត រិទ្ធ** រដ្ឋលេខាធិការក្រសួងយុត្តិធម៌ បើយើងចង់បានដំណោះស្រាយអន្តរកាល គឺយើងមិនពន្លាតរឿងព្រហ្មទណ្ឌទេ តែអន្តរការីត្រូវតែមានទោស ព្រោះច្បាប់យើងបានចែងច្បាស់ហើយ កុំបារម្ភថាអ្នកផ្សេងអត់ចេញមុខ អន្តរការីគាត់នឹងផ្តល់ព័ត៌មានពីឪពុកម្តាយចង់បានក្មេង ដឹងតែចេញមុខមកហើយ។ ក្មេងដែលនាំយកទៅក្រៅប្រទេស គួរតែឆ្លងតុលាការ បើមិនដូច្នេះទេរឿងនឹងថ្ងៃក្រោយដឹងតែកើតមានទៀត មួយទៀតបើកម្ពុជាចង់បើកទូលាយទីផ្សារពពោះនេះ គ្រាន់តែពន្យារពេលបង្កើតច្បាប់ ឬច្បាប់នឹងអត់ចេញ គឺទីផ្សារនឹងកើតមានតែម្តង។ បើយើងបង្កើតគោលនយោបាយទៅថ្ងៃក្រោយក្នុងការហាមឃាត់លើករណីនេះ មានវិធានការពីរ ទី១ គឺវិស័យសុខាភិបាលតាមរយៈការរឹតបន្តឹងតាម គ្លីនីក ទី២ គឺការទទួលខុសត្រូវតាមព្រហ្មទណ្ឌ បើអត់មានចែងទេយើងប្រកាសហាមយ៉ាងណា ក៏ហាមមិនកើតដែរ ហើយច្បាប់ពពោះត្រូវកំណត់ពេលកូនកើតមកត្រូវធ្វើយ៉ាងដូចម្តេច? រឿងនឹងសំខាន់ជាងគេ បើប្រកាសតែមិនដាក់ទណ្ឌកម្មលើគាត់ គឺគាត់មិនខ្លាចទេ។

ប្រសាសន៍ **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ អ្វីដែលយើងបានពិភាក្សាគ្នារកដំណោះស្រាយកន្លងមក គឺយើងបានទុកផ្លូវឲ្យដើរ បើយើងធ្វើការរឹតបន្តឹងតាមច្បាប់ព្រហ្មទណ្ឌ គឺយើងធ្វើការស្រាវជ្រាវ និងឃាត់ខ្លួនហើយ ប៉ុន្តែអ្វីដែលយើងបានដោះស្រាយករណីពពោះនេះដែលបានជ្រុលហួសទៅហើយ ក្នុងពេលដែលយើងកំពុងរកដំណោះស្រាយ គឺត្រូវតែបានទទួលនូវការដោះស្រាយដើម្បីផលប្រយោជន៍របស់ទារកនោះ ដោយសារឪពុកម្តាយបានយល់ព្រមឲ្យកូន ឬមួយខ្លួនគាត់ពពោះ គាត់ផ្អែកលើហេតុផលតែមួយទេ គឺគ្រួសារក្រីក្រត្រូវការលុយ បើកូននឹងកើតមកល្អគេឲ្យលុយពេញ បើមិនល្អគេមិនយកហើយជួនកាលត្រូវបានគេទម្លាក់ថ្លៃ នេះគឺជាការតថ្លៃទារកនៅក្នុងផ្ទៃ បើទារកដែលកើតមកមិនត្រូវបានគេយកហើយម្តាយដែលជាអ្នកពពោះមិនយកដែរដោយហេតុថាគាត់មិនចង់បាន ដូច្នេះកូននឹងត្រូវក្លាយជាកម្មវត្ថុ នៃអំពើរងគ្រោះ។ ការដោះស្រាយនឹងធ្វើទៅតាមករណី ប៉ុន្តែការដោះស្រាយនោះពុំទាន់ដឹងថាយ៉ាងណាទេ ពីព្រោះកំពុងតែពិភាក្សា ប៉ុន្តែបើយើងធ្វើការដោះស្រាយ គឺយើងធ្វើការដោះស្រាយដោយមិនយកតាមច្បាប់ស្មុំកូនទាំងស្រុងនោះទេ ព្រោះវានឹងពាក់ព័ន្ធជាមួយឪពុក យើងគ្រាន់តែយកលំនាំតាមច្បាប់ នៃការពពោះដោយមានលក្ខខណ្ឌមួយចំនួនដូចគ្នា ហើយបន្ថែមទៅលើការផ្ទេរសិទ្ធិអាណាព្យាបាល តែកូននឹងនៅតែជាកូនរបស់ម្តាយនឹងដដែល។ យើងត្រូវធ្វើការផ្សព្វផ្សាយដែរទៅដល់អ្នកដែលមានបំណងចង់ធ្វើ គឺត្រូវតែទទួលទោសដាច់ខាត សម្រាប់អ្នកដែលបានពពោះជ្រុលហួសហើយមិនអីទេ តែត្រូវមានពេលកំណត់យ៉ាងយូរត្រឹមដាច់ឆ្នាំនេះអស់ហើយ។ ប្រទេសយើងមានច្បាប់ កុំឲ្យប្រទេសគេមើលងាយច្បាប់កម្ពុជាយើង ដោយគ្រាន់តែយក ឌីអិនអេ ហើយធ្វើការអន្តោគមន៍យើងឲ្យចេញ ដូច្នេះវាធ្វើឲ្យច្បាប់ជាតិយើងធ្លាក់ចុះនូវគុណតម្លៃ។

ប្រសាសន៍ **ឯកឧត្តម សុខ ផល** អគ្គនាយក នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ករណីនេះមានការពាក់ព័ន្ធពីរចំណុច ចំណុចទី១ ទាក់ទងនឹងកិច្ចការអន្តោប្រវេសន៍ នៃនាយកដ្ឋានអន្តោប្រវេសន៍ ក្នុងការចេញ Exit Visa ដំបូងយើងមិនបានដឹងទេក្នុងរឿងនេះ ខ្ញុំបានធ្វើរបាយការណ៍ដើម្បីសុំជាគោលការណ៍ដឹកនាំរបស់ **សម្តេចក្រឡាហោម** ដែរ។ អ្វីដែលចាប់អារម្មណ៍គឺដំណោះស្រាយក្នុងអន្តរកាល បើតាមការសំណូមពររបស់ជនបរទេសបានមកសុំ គឺយើងអាចបែងចែងប្រភេទអន្តរកាលនេះជាពី ទី១ គឺអន្តរកាល១០នាក់ ដែលបានដាក់ពាក្យបន្តរួចហើយមកយើង ទី២ អន្តរកាលអ្នកដែលកើតហើយអាចមានច្រើនទៀត ដែលយើងក្តាប់មិនទាន់បានអស់។ ចំណុចទី២ ក្រោយកើតរឿងនេះខ្ញុំបានធ្វើការស្រាវជ្រាវនៅបណ្តាប្រទេសមួយចំនួនដែរ ពាក់ព័ន្ធនៅប្រទេសថៃ បានចេញច្បាប់នៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៥ មកនេះ មិនមែនកំណត់តែប្តីប្រពន្ធថៃទេ គឺគេក៏បានកំណត់អាពាហ៍ពិពាហ៍ឆ្លងសញ្ជាតិដែរ តែច្បាប់កំណត់ថាប្តីប្រពន្ធការបានបីឆ្នាំ ហើយភាគីខាងនារីមិនមានលទ្ធភាពមានកូនបាន ទើបអាចយកទៅឲ្យគេពពោះបាន។

ប្រសាសន៍ **ឯកឧត្តម ស៊ា កុសល** អនុរដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ករណីចំណងវាងម្តាយ និងកូន អ្វីដែលសំខាន់គឺសញ្ជាតិ តាមច្បាប់សញ្ជាតិប្រទេសកម្ពុជាយើង មាត្រា៤ បានចែងថា កាលណាទារកកើតពីឪពុកម្តាយមានសញ្ជាតិខ្មែរ ទារកត្រូវមានសញ្ជាតិខ្មែរ ដូច្នេះ គឺច្បាស់លាស់ យើងត្រូវរកដំណោះស្រាយជូនពលរដ្ឋរបស់យើង ឥឡូវទារកបានកើតមកហើយយើងត្រូវធ្វើដូចម្តេច ដើម្បីជាផលប្រយោជន៍ទារកនឹង? យើងត្រូវធ្វើការដោះស្រាយតាមនីតិវិធីសុំកូន ដូចដែល **លោកជំទាវ ជូ ប៊ុនអេង** និង**ឯកឧត្តម កើត រិទ្ធ** បានលើកឡើង ទារកមានសញ្ជាតិពីរ ដែលជាពលរដ្ឋយើងសុទ្ធសាធ តែគេយកទៅប្រទេសគេ ទូតអាមេរិក ទូតអូស្ត្រាលី ទូតកាណាដា គេមានប៉ាស្ព័រទារកមុនយើងទៅទៀត រដ្ឋគេគាំទ្រពលរដ្ឋគេដែលជាទារកមានសញ្ជាតិពីរ យើងដោះស្រាយតាមបែបនឹងបានតែត្រូវក្នុងករណីពិសេស ផ្តាច់ចំណងវាងម្តាយ និងកូនបាន តែមិនអាចកាត់ផ្តាច់វាងទារក និងរដ្ឋយើងបានទេ លុះត្រាតែទារកនឹងមានអាយុ១៨ឆ្នាំសិន ហើយគាត់សុំលាលែងសញ្ជាតិទើបអាចផ្តាច់បាន។

ប្រសាសន៍ **សម្តេចក្រឡាហោម ស ខេង** តើខាងអគ្គនាយកដ្ឋានអត្តសញ្ញាណកម្មមានបានដឹងថាក្មេងទាំងអស់នឹងបានចុះបញ្ជីជាតិ ឬសំបុត្រកំណើតទេ? ដំណោះស្រាយនេះយើងត្រូវគិតពីសិទ្ធិ និងផលប្រយោជន៍របស់ក្មេងជាមូលដ្ឋាន ហើយសំខាន់ គឺគោលការណ៍យើងប្រឆាំងការជួញដូរមនុស្ស ដូច្នេះយើងត្រូវរកវិធីយ៉ាងណាដើម្បីធានាថាក្មេងនោះមិនត្រូវបានក្លាយជាមុខសញ្ញា នៃការជួញដូរ ឬអំពើហិង្សាផ្សេងៗ ធានាថាខ្លួនអត់មានកូនចង់បានកូនយកទៅចិញ្ចឹម តែប្រែក្លាយទៅជាការជួញដូរទៅវិញ។ យើងមិនត្រូវរើតបន្តឹងច្បាប់ មានន័យថាបង្កបញ្ហានឹង ធ្វើឲ្យអនាគតក្មេងនឹងតែលតោលជួបការលំបាក គ្មានអ្នកណាទទួលខុសត្រូវ បញ្ហានេះនឹងធ្លាក់មកលើអាជ្ញាធររដ្ឋរបស់យើង ទាំងសុខភាពនិងការសិក្សារៀនសូត្ររបស់ក្មេង ហើយមួយទៀតបើជាលក្ខណៈសុំកូនត្រូវឲ្យខាងអ្នកសុំកូនធ្វើជារបាយការណ៍យ៉ាងយូរ១ឆ្នាំម្តង ដើម្បីធ្វើការតាមដានអំពីការវិវឌ្ឍរូបរាង នៃក្មេងនោះ។

ប្រសាសន៍ **ឯកឧត្តម នាយឧត្តមសេនីយ៍ ម៉ៅ ច័ន្ទតារា** អគ្គនាយក នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម រឿងនេះ គឺជារឿងថ្មីរបស់អគ្គនាយកដ្ឋានអត្តសញ្ញាណកម្មដែរ ផ្អែកតាមអនុក្រឹត្យ១០៣ ដែល

និយាយពីអត្រានុកូលដ្ឋានបានកំណត់ថា ជនបរទេសដែលបានចុះអត្រានុកូលដ្ឋាន លុះត្រាតែជនបរទេសរូបនោះរស់នៅស្របច្បាប់កម្ពុជា ចុងក្រោយនេះពាក់ព័ន្ធនឹងនីតិវិធីក្រមព្រហ្មទណ្ឌ ការចុះសំបុត្រកំណើតនេះ ទារកដែលមានឪពុកម្ដាយជាជនជាតិខ្មែរ ឬប្ដីប្រពន្ធពីរនាក់មានម្នាក់ជាជនជាតិខ្មែរ គឺយើងអនុញ្ញាតឲ្យចុះបញ្ជីបានទោះបីជាកូននោះមាន ឬអត់ខាន់ស្លាក៏ដោយ។ យើងត្រូវមានការបន្ថែមទៀត ឬមានការកំណត់បែបបទនីតិវិធីដើម្បីកុំឲ្យមានបញ្ហាកើតឡើងទៀត បើយើងចង់បញ្ចប់នូវបញ្ហានេះ គឺយើងត្រូវដោះស្រាយតាមច្បាប់ស៊ីវិល និងច្បាប់ព្រហ្មទណ្ឌ ដូច្នេះគួរតែកំណត់រយៈពេលណាមួយដែលត្រូវបញ្ចប់ អ្នកមានបញ្ហាបន្តទៀតត្រូវតែអនុវត្តតាមច្បាប់ព្រហ្មទណ្ឌ បើមិនមានវិធានការតឹងរឹងនោះទេ វានឹងមានបញ្ហាដដែលៗកើតឡើងជាបន្តទៀត។ រីឯបញ្ហាមនុស្សធម៌ បើយើងមិនដោះស្រាយទេ សួរថាអ្នកណាជាអ្នកដោះស្រាយក្មេងដែលមិនដឹងអីសោះ?

ប្រសាសន៍ **ឯកឧត្ដម កើត រិទ្ធ** ពេលឯកឧត្ដម ស៊ា កុសល និងឯកឧត្ដម ម៉ៅ ច័ន្ទតារា បានលើកឡើងខ្ញុំបានមើលឃើញពីចំណុចធំមួយ គឺយើងរកតុល្យភាពរវាងប្រឆាំងការជួញដូរ និងផលប្រយោជន៍អនីតិជន ហើយប្រយោជន៍របស់ក្មេងនឹងមាន សញ្ជាតិខ្មែរ និងបរទេស ប៉ុន្តែក្មេងនេះអត់មាន ឌីអិនអេ របស់ម្ដាយទេ ហើយម្ដាយដឹងច្បាស់ថា កូននឹងមិនមែនជាកូនរបស់គាត់ទេ បញ្ហាត្រង់ថាជាក់ស្ដែងកូននេះមិនមែនជាកូនគាត់ទេ តើត្រូវដោះស្រាយជាប្រយោជន៍ឲ្យក្មេង ត្រូវដោះស្រាយក្នុងន័យយ៉ាងណា? ដំណោះស្រាយមិនត្រូវគិតពីមនុស្សធម៌មួយទេ ដំណោះស្រាយមនុស្សធម៌មិនស្ថិតស្ថេរយូរអង្វែងទេ ហើយបើយើងដោះស្រាយហើយវានឹងកើតឡើងមកទៀត មួយហើយមួយទៀតដោយសារគិតទៅលើប្រយោជន៍ក្មេង ឲ្យចេញរហូតគ្រប់ករណីទាំងអស់។ ដូច្នេះផ្អែកលើផ្លូវច្បាប់ យើងផ្ដល់អាទិភាពផលប្រយោជន៍សម្រាប់កុមារ គោលនយោបាយយើង ធ្វើច្បាប់ពពោះបានហើយតើយើងអាចទប់បានអត់? បើផ្អែកតាមទិដ្ឋភាពច្បាប់ នៃក្រមព្រហ្មទណ្ឌបើម្ដាយមិនមើលថែកូនទេ ម្ដាយត្រូវជាប់គុក ប៉ុន្តែជាក់ស្ដែងគាត់អត់មើល គាត់ថាមិនមែនជាកូនគាត់ ហើយគាត់មិនមានលទ្ធភាព ដូច្នេះក្មេងនឹងអាចមានបញ្ហា ឬស្លាប់ទៅវិញ សូមឲ្យសម្ដេច ក៏ដូចជាលោកជំទាវ រដ្ឋមន្ត្រីក្រសួងកិច្ចការនារី គិតគូរពីជ្រុងនេះជាគោលនយោបាយ។ ខ្ញុំសូមសំណូមពរមួយជាមួយដំណោះស្រាយតាមបែបស៊ីវិល ដើម្បីឲ្យកូននេះចេញទៅក្រៅប្រទេសដោយច្បាស់លាស់ត្រឹមត្រូវគួរឆ្លងតុលាការដើម្បីប្រគល់សិទ្ធិឲ្យឪពុកគ្រប់គ្រងលើក្មេងនេះ កុំឲ្យប្រើកិច្ចសន្យា ហើយម្ដាយត្រូវមានសិទ្ធិដឹងពីកូនរបស់គាត់ ទោះបីកូននោះជាកូនបង្កើតឡើងដោយសារអ្វីក៏ដោយ ព្រោះកូននោះក៏មានឈាមគាត់នៅជាមួយដែរ ហើយកូននោះក៏មានសិទ្ធិចង់ដឹងថាអ្នកណាជាម្ដាយរបស់គាត់ដែរ។ ដើម្បីធ្វើការទប់ស្កាត់ក្នុងករណីនេះ យើងត្រូវជំរុញការបង្កើតច្បាប់នេះឲ្យបានឆាប់ និងគ្រប់គ្រងឲ្យបានតឹងរឹងលើគ្លីនិកឯកជន និងការចុះសំបុត្រកំណើត។

ប្រសាសន៍ **ឯកឧត្ដម ម៉ម ប៊ុនហេង** បើយើងបិទក៏មិនកើត ហើយបើកត្រូវមានលក្ខខណ្ឌ ដូចក្នុងករណីប្ដីប្រពន្ធ ដោយប្រពន្ធមានបញ្ហាមិនអាចមានកូនបានដូច្នេះពួកគេនឹងត្រូវស្វែងរកសេវាពពោះ តែបើយើងបិទពេកគេនឹងទៅរកនៅក្រៅប្រទេសគេយកលុយដដែល ពេលមានបញ្ហាធ្លាក់មកលើយើង ហើយការផ្ដល់សេវាពពោះសម្រាប់ប្ដីប្រពន្ធដែលមានសញ្ជាតិខ្មែរតែប៉ុណ្ណោះ ការឲ្យពពោះជំនួសនេះបានសម្រាប់តែសាច់ញាតិខ្លួនតែប៉ុណ្ណោះ។ ឧទាហរណ៍ មានប្ដីប្រពន្ធសាសន៍ដទៃ គេមករកសេវានៅស្រុកយើងតើយើងត្រូវធ្វើការហាមឃាត់ដែរឬទេ? យើងហាមឃាត់តែសេវាទេ ព្រោះនៅប្រទេសគេ គេបានប្រើសេវានេះដែរទោះបីជាគេមានច្បាប់ទាក់ទងនឹង

ករណីនេះក៏ដោយ ប៉ុន្តែបើយើងរឹតបន្តឹងពេកក្នុងការជួយស្ត្រីដែលកំពុងពពោះគាត់មានការភ័យខ្លាច ហើយពេទ្យក៏ភ័យដែរលែងហ៊ានជួយទៅទៀត ដូច្នេះត្រូវដោះស្រាយដោយទន់ភ្លន់ និងជាប្រយោជន៍ដល់ម្តាយ និងទារកផង។

ប្រសាសន៍ **លោកជំទាវ អ៊ឹង កន្ថាផាវី** រដ្ឋមន្ត្រីក្រសួងកិច្ចការនារី ករណីនៅប្រទេសថៃកន្លងមកដែលត្រូវពិចារណាឡើងវិញ មានករណីមួយដែលកូនកើតមកមានជំងឺផ្នែកខួរក្បាល កូននឹងមានម្តាយឪពុក(អ្នកចង់បានកូន)ជាអូស្ត្រាលីហើយចង់ទៅរស់នៅប្រទេសអូស្ត្រាលីវិញ តែម្តាយដែលជាអ្នកពពោះជំនួសនោះគាត់បានទាមទារទៅមើលថែកូននោះនៅអូស្ត្រាលីដែរ ដោយយោងតាមច្បាប់ប្រទេសថៃថាគាត់ជាអ្នកពពោះ ដូច្នេះគាត់ជាម្តាយពេញសិទ្ធិ។ ទាក់ទងនឹងករណីខាងលើខ្ញុំគិតថា គួរប្រើប្រាស់នីតិវិធីសុំកូនពេញលេញក្នុងការកាត់ផ្តាច់ចំណងរវាងកូន និងម្តាយដែលពពោះ ដើម្បីកុំឲ្យម្តាយគាត់ធ្វើការទាមទារទៅតាមកូននោះនៅក្រៅប្រទេសដែរ។

ប្រសាសន៍ **លោកជំទាវ ច័ន្ទ ហារ៉ានវឌ្ឍី** អនុរដ្ឋលេខាធិការក្រសួងសង្គមកិច្ច **អតីតយុទ្ធជន និងយុវនីតិសម្បទា** ករណីការសុំកូនដែលអង្គប្រជុំបានលើកនេះ គឺជាការសុំកូនអន្តរប្រទេសព្រោះឪពុកជាជនជាតិបរទេស នៅក្នុងច្បាប់សុំកូនអន្តរប្រទេសបានអនុញ្ញាតឲ្យអ្នកសុំដែលជាឪពុក ឬម្តាយរបស់កូននោះ ដូច្នេះការអនុវត្តនីតិវិធីសុំកូនអន្តរប្រទេសនេះ មិនអាចធ្វើបានទេ តាមមាត្រា១ នៃច្បាប់សុំកូន លុះត្រាតែប្រទេសនោះបានចុះ MOU ជាមួយប្រទេសកម្ពុជាយើង ហើយតឹងរឹងជាងគេគឺ សហរដ្ឋអាមេរិក បើអាមេរិកព្រមធ្វើ ប្រទេស៥ ទៀតនឹងធ្វើតាម ដូចជា អង់គ្លេស កាណាដា អូស្ត្រាលី បារាំង ក៏អត់ដែរ។

ប្រសាសន៍ **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ បញ្ហាដោះស្រាយចំពោះមុខរបស់យើងគឺ អនុវត្តតាមនីតិវិធីសុំកូន តែច្បាប់មិនអនុញ្ញាតដោយសារមិនទាន់បានចុះអនុស្សរណៈដូច្នេះយើងយកវិធីណា? យើងត្រូវបំពេញកាតព្វកិច្ចរបស់អាជ្ញាធរដើម្បីផលប្រយោជន៍សម្រាប់ពលរដ្ឋយើង និងការពារមិនឲ្យមានការជួញដូរផង ហើយក្នុងគោលបំណងទប់ស្កាត់ការពពោះផងកុំឲ្យរីករាលដាល។ ជម្រើសអង្គប្រជុំដែល **លោកជំទាវ ជូ ប៊ុនអេង** ដឹកនាំគឺជម្រើសមានពីរ ទី១ ការអនុវត្តដំណោះស្រាយតាមច្បាប់ស៊ីវិលករណីកំពុងកើតមាន និងទី២តាមច្បាប់ព្រហ្មទណ្ឌ វាមានផលប៉ះពាល់ដល់ក្មេង នេះបើតាមមាត្រា ៣៣២ នៃក្រមព្រហ្មទណ្ឌ។ យើងនៅរង់ចាំការធ្វើសេចក្តីព្រាងច្បាប់ថ្មីរបស់**លោកជំទាវ អ៊ឹង កន្ថាផាវី** រដ្ឋមន្ត្រីក្រសួងកិច្ចការនារី និងសូមឲ្យមានការសហការគ្នាលើកិច្ចការនេះឲ្យបានឆាប់។ ខ្ញុំសូមឲ្យ**លោកជំទាវ ជូ ប៊ុនអេង** ធ្វើរបាយការណ៍ព្រាងដើម្បីរាយការណ៍ និងសុំយោបល់ពី សម្តេចតេជោ នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ព្រោះតាមបែបបទការងាររបស់យើង គឺត្រូវតែសុំយោបល់អំពីការសម្រេច និងឯកភាព។ សូមស្នើ**ឯកឧត្តម កើត រិទ្ធ** និង**ឯកឧត្តម ប៉ុល លឹម** ជួយមើលថែមទៀតដើម្បីឲ្យសមស្របមុនខ្ញុំចុះហត្ថលេខា ហើយនិងខាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិជួយព្រាងអំពីវិធានការ នៃការដោះស្រាយករណីនេះ សូមបញ្ជាក់ថាដោះស្រាយបញ្ហាដែលមានហើយ អនុវត្តតាមច្បាប់រដ្ឋប្បវេណី ការងារនេះត្រូវគិតពីសិទ្ធិ និងផលប្រយោជន៍របស់ប្រជាពលរដ្ឋខ្មែរយើងផង ត្រូវមានគោលការណ៍ឲ្យបានសមស្របកុំឲ្យមានការស្តាំពេក ឬឆ្វេងពេក ត្រូវធ្វើការជ្រើសរើសត្រឹមត្រូវប្រកាន់យកកណ្តាល ព្រោះស្ត្រីខ្មែរយើងក្រីក្រ លំបាក ហើយគាត់មេម៉ាយទៀតគាត់ចង់បានលុយដើម្បីចិញ្ចឹមជីវិត។ យើងត្រូវគិតពីឱសានវាទ នៃបញ្ហានេះដើម្បីកុំឲ្យបញ្ហានេះ ចេះតែកើតមានថែមបន្តទៀត យើងដោះស្រាយបញ្ហា

ដែលមានស្រាប់ហើយបានដាក់មានលិខិតចូល។

អង្គប្រជុំពិភាក្សាបានបញ្ចប់នៅវេលាម៉ោង ដប់មួយ និងសាមសិបនាទី ថ្ងៃខែឆ្នាំដដែល។

រាជធានីភ្នំពេញ ថ្ងៃទី២១ ខែ កុម្ភៈ ឆ្នាំ២០១៧

**អ្នកធ្វើកំណត់ហេតុ**

kamol

**គោរពជូន**

**លោកជំទាវអនុប្រធានអចិន្ត្រៃយ៍**

មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់។

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ កុម្ភៈ ឆ្នាំ២០១៧

ប្រធានលេខាធិការដ្ឋាន

ឧត្តមសេនីយ៍ត្រី គង់-ពុទ្ធិ

បានឃើញ

28/02/2017

ជូ-ម៉ុនអេង

# សមាសភាពអញ្ជើញចូលរួម
## កិច្ចប្រជុំពិភាក្សាស្តីពី "ដំណោះស្រាយបញ្ហាពពោះជំនួស" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់
## សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
## និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
## សាលប្រជុំក្រសួងមហាផ្ទៃ ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៧

| | | |
|---|---|---|
| ១.ឯកឧត្តម | ហង់ ជួនណារ៉ុន | រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា |
| ២.ឯកឧត្តម | ម៉ម ប៊ុនហេង | រដ្ឋមន្ត្រីក្រសួងសុខាភិបាល |
| ៣.ឯកឧត្តម | អង្គ វង្សវឌ្ឍនា | រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ |
| ៤.ល.ជំរដ្ឋបណ្ឌិត | អ៊ឹង កន្ថាផាវី | រដ្ឋមន្ត្រីក្រសួងកិច្ចការនារី |
| ៥.លោកជំទាវ | ជូ ប៊ុនអេង | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ |
| ៦.ឯកឧត្តម | អ៊ុក គឹមលេខ | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ |
| ៧.ឯកឧត្តម | កើត រិទ្ធ | រដ្ឋលេខាធិការក្រសួងយុត្តិធម៌ |
| ៨.ឯកឧត្តម | ប៉ុល លឹម | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ |
| ៩.លោកជំទាវ | ច័ន្ទ ហាក់នវឌ្ឍី | អនុរដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| ១០.ឯកឧត្តម | សុខ រឿន | អគ្គព្រះរាជអាជ្ញារង មហាអយ្យការសាលាឧទ្ធរណ៍ |
| ១១.លោកជំទាវ | សួស វឌ្ឍារី | អនុរដ្ឋលេខាធិការក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ |
| ១២.ឯកឧត្តម | ស៊ា កុសល | អនុរដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ |
| ១៣.លោកជំទាវ | ប៊ុន ពុទ្ធី | អនុរដ្ឋលេខាធិការក្រសួងកិច្ចការនារី |
| ១៤.ឯ.ឧ.នាយ | នេត សាវឿន | អគ្គស្នងការ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ |
| ១៥.ឯ.ឧ.នាយ | សុខ ផល | អគ្គនាយក នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ |
| ១៦.ឯ.ឧ.នាយ | ម៉ៅ ច័ន្ទតារា | អគ្គនាយក នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម |
| ១៧.ឯ.ឧ.ឧ.ឯក | ហ៊ោង សំអាត | អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ |
| ១៨.ឯ.ឧ.ឧ.ឯក | យឹម រិះ | អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ |
| ១៩.ឯកឧត្តម | អ៊ូច ចាន់ណូរ៉ា | អគ្គនាយករង អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម |
| ២០.លោកជំទាវ | មឿង ស៊ាងសេង | នាយករងខុទ្ទកាល័យ |
| ២១.ឯកឧត្តម | ម៉ែន ប៊ុនរិទ្ធ | អគ្គលេខាធិការរង ក្រសួងមហាផ្ទៃ |
| ២២.ឯកឧត្តម | សូរ ឌីម៉ា | អនុប្រធានក្រុមប្រឹក្សានីតិកម្ម |
| ២៣.លោកជំទាវ | រ៉ែន សិរីលក្ខិណា | អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ |
| ២៤.ឯកឧត្តម | ឱ វណ្ណឌីន | អគ្គនាយក ក្រសួងសុខាភិបាល |

| | | |
|---|---|---|
| ២៥.ឯ.ឧ.ឧ.ឯក | ហាស់ ម៉េងឡុង | អគ្គនាយករង នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ |
| ២៦.ឯ.ឧ.ឧ.ឯក | ប៉ុល ភិធេយ្យ | ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ |
| ២៧.លោក | រស់ ពិសិដ្ឋ | ចៅក្រម សាលាដំបូងរាជធានីភ្នំពេញ |
| ២៨.លោក | សេង ហៀង | ព្រះរាជអាជ្ញារង អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ |
| ២៩.លោក | គី ខេមលីន | អគ្គនាយករង ក្រសួងយុត្តិធម៌ |
| ៣០.លោកស្រី | សារឿន សាវ៉ាតឌី | អគ្គនាយករង ក្រសួងកិច្ចការនារី |
| ៣១.លោក | តែ សុខា | ជំនួយការ រដ្ឋមន្ត្រីក្រសួងកិច្ចការនារី |
| ៣២.លោក | ម៉ុក សារ៉ុម | អគ្គនាយករង ក្រសួងអប់រំ |
| ៣៣.លោក | ឈា ធវណ្ណ | នាយកវិទ្យាស្ថាន ក្រសួងសុខាភិបាល |
| ៣៤.លោកស្រី | ព្រុំ សុខន | ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្សក្រសួងសង្គមកិច្ច |
| ៣៥.លោក | សុខ វាសនា | ប្រធាននាយកដ្ឋានជនបរទេស មិនមែនអន្តោប្រវេសន៍ និងបច្ចេកវិទ្យា |
| ៣៦.លោកឧ.ត្រី | គង់ ពុទ្ធី | ប្រធានលេខាធិការដ្ឋានរដ្ឋបាលសរុប គ.ជ.ប.ជ |
| ៣៧.លោក វ.ឯក | កែវ សុវណ្ណារ៉ា | ប្រធាននាយកដ្ឋាន គ.ជ.ប.ជ |
| ៣៨.លោក វ.ឯក | ហាង ជីវ័ន្ត | អនុប្រធានលេខាធិការដ្ឋានរដ្ឋបាលសរុប គ.ជ.ប.ជ |
| ៣៩.លោក | ធូ ចាន់ដារ៉ា | ជំនួយការរដ្ឋលេខាធិការ អគ្គលេខាធិការដ្ឋាន |
| ៤០.លោក | ណុប រដ្ឋា | ប្រធានការិយាល័យ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ |
| ៤១.លោក | ទុយ ច័ន្ទ | ជំនួយការ |
| ៤២.លោក | អ៊ិន មាន | ជំនួយការ |
| ៤៣.លោក | អ៊ុំ កាមិន្ទ | ប្រធានការិយាល័យផ្សព្វផ្សាយ អប់រំ (គ.ជ.ប.ជ) |
| ៤៤.លោក | ឱក សត្យា | អនុប្រធានការិយាល័យផ្សព្វផ្សាយ អប់រំ (គ.ជ.ប.ជ) |
| ៤៥.លោក | ដៀប នួច | អនុប្រធានការិយាល័យផ្សព្វផ្សាយ អប់រំ (គ.ជ.ប.ជ) |
| ៤៥.លោក | សៅ ស៊ីនួន | អនុប្រធានការិយាល័យផ្សព្វផ្សាយ អប់រំ (គ.ជ.ប.ជ) |

**សរុប៖ ៤៤ រូប ស្រី ០៨ រូប**